FLO
Building Resourceful Communities

ALiSEA

# សារៈសំខាន់នៃការបង្កើតកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើ និងការគ្រប់គ្រងការងារកសិរុក្ខកម្ម

Dete : 28 March 2025

Presented by :

Mrs. Kann Seyma

FLO
Building Resourceful Communities

ALiSEA

# មាតិកា



១.និយមន័យ និងប្រព័ន្ធកសិរុក្ខកម្ម

២.ការអនុវត្តន៍កសិរុក្ខកម្មនៅតំបន់ត្រូពិច

៣.សារៈសំខាន់និងជំហាននៃការបង្កើតកសិរុក្ខកម្ម

៤.ការចែករំលែកបទពិសោធន៍នៃការបង្កើត និងការគ្រប់គ្រងកសិរុក្ខកម្ម

៥.សំណួរ-ចម្លើយ






# Our Vision

Local communities in northeastern Cambodia enjoy ownership rights over their natural resources and exercise their rights for dignified sustainable livelihoods.

# Our Mission

FLO helps the **local communities** to practice **sustainable natural resource management** and improve their livelihoods through wise socio-economic development. FLO supports the communities to strengthen their advocacy capacities for the **recognition of their tenure** over their natural resources






# 15 years experience on the field

## Non-profit

local organization

## Based in Kratie

• with a team from different provinces in cambodia

## Since 2010

• registered at the Ministry of Interior in December 2010



- 1. កសិរុក្ខកម្ម សំដៅលើចេតនាក្នុងការរួមបញ្ចូលដើមឈើ ទៅក្នុងប្រព័ន្ធដំណាំកសិកម្ម និងការចិញ្ចឹមសត្វ ដើម្បីបង្កើតជាផលចំណេញ ដល់បរិស្ថាន សេដ្ឋកិច្ច និងសង្គម។កសិរុក្ខកម្មត្រូវបានចាត់ទុកជាប្រព័ន្ធនៃការប្រើប្រាស់ដីយ៉ាងសមស្របបំផុតដោយបំពេញបានតាមគោលបំណងទាំងពីរគឺ៖ សេដ្ឋកិច្ច និងភាពធន់ទ្រាំនៃបរិស្ថានធម្មជាតិ (ASEAN,2018) ។

# ១.និយមន័យកសិរុក្ខកម្ម



**What is Agroforestry ?**

**តើអ្វីទៅជាកសិរុក្ខកម្ម?**





# ១.និយមន័យកសិរុក្ខកម្ម




**កសិរុក្ខកម្ម** ជាប្រព័ន្ធប្រើប្រាស់ដីធ្លីតាមបែបបុរាណនិងសម័យ  ដែលដើមឈើត្រូវបានគ្រប់គ្រងរួមគ្នាជាមួយដំណាំនិង/ឬប្រព័ន្ធផលិតកម្មសត្វនៅក្នុងការរៀបចំធ្វើកសិកម្ម។កសិកម្មជាប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិមានភាពប្រែប្រួលដោយផ្អែកលើមូលដ្ឋានអេកូឡូស៊ី ជាប្រព័ន្ធគ្រប់គ្រងធម្មជាតិដែលមានភាពចម្រុះនិងធានានូវផលិតភាព ដើម្បីបង្កើនអត្ថប្រយោជន៍សង្គម សេដ្ឋកិច្ចនិងបរិស្ថានសម្រាប់អ្នកប្រើប្រាស់ដីនៅគ្រប់លំដាប់(FAO )។

**2.កសិរុក្ខកម្ម** គឺជាប្រព័ន្ធនៃការប្រើប្រាស់ដី ដែលមានដាំដើមឈើ ដំណាំ មនុស្សសត្វ នៅលើផ្ទៃដីតែមួយក្នុងគោលបំណងទទួលបាននូវផលិតភាពខ្ពស់ ចំណេញច្រើន ដោយស្ថិតនៅលើគោលការណ៍និរន្តរភាព(គឺការប្រើប្រាស់ធនធានដែលធានានូវភាពសំបូររុងរឿងដល់មនុស្សជំនាន់ក្រោយ)(អង្គការជីរេស)។



**3.កសិរុក្ខកម្ម** គឺជាការដាំកូនឈើនិងដំណាំនៅលើដីកសិដ្ឋាននៅជុំវិញផ្ទះ ដីដែលកំពុងប្រើប្រាស់ឬដីចម្ការដែលនៅទំនេរ។កសិរុក្ខកម្មអាចកាន់តែធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ដីដែលទំនេរ  ដើម្បីទាញយកផលពីការដាំដុះកូនឈើនិងដំណាំរួមផ្សំផ្សេងៗ ក្នុងកម្រិតខ្ពស់គួរជាទីគាប់ចិត្ត(វិទ្យាស្ថានស្រាវជ្រាវនិងបណ្តុះបណ្តាល ២០១៤)។



# ១.និយមន័យកសិរុក្ខកម្ម

- **និយមន័យរួម**

**កសិរុក្ខកម្ម** គឺជាការប្រើប្រាស់ដីរួមគ្នារវាងការអនុវត្តដំណាំកសិកម្ម រួមជាមួយដើមឈើ ហើយដែលមានអន្តរកម្មឱ្យគ្នាទៅវិញទៅមក ដើម្បីទទួលបាននូវផលិតភាពខ្ពស់ ផលចំណេញផ្នែកបរិស្ថាន សេដ្ឋកិច្ចនិងសង្គមប្រកបដោយ និរន្តរភាព (សិក្ខាសាលាពិគ្រោះយោបល់ខែមិថុនា ឆ្នាំ ២០២៣)។



# ➢ ធាតុសំខាន់នៃកសិរុក្ខកម្ម










## ➢ ចំណាត់ថ្នាក់នៃប្រព័ន្ធកសិរុក្ខកម្ម

1. ប្រព័ន្ធកសិរុក្ខវប្បកម្ម
*(Agri-silvicultursl system)*



2. ប្រព័ន្ធបសុរុក្ខវប្បកម្ម
*(Silvi-Pastoral system)*

3. ប្រព័ន្ធកសិបសុរុក្ខវប្បកម្ម
*(Agri-Silvi-Pastoral System)*

4. ប្រព័ន្ធកសិរុក្ខកម្មចម្រុះ
*(Integrated Agroforestry System)*

# ➢ ចំណាត់ថ្នាក់នៃប្រព័ន្ធកសិរុក្ខកម្ម(ត)

1. ប្រព័ន្ធកសិរុក្ខវប្បកម្ម

*(Agri-silvicultursl system)*

➢ ប្រព័ន្ធកសិរុក្ខវប្បកម្មសំដៅលើការដាំដំណាំកសិកម្ម និងដើមឈើ (ដែលដាំដុះបញ្ចូលគ្នារវាងដំណាំកសិកម្ម និង ព្រៃឈើ កូនឈើ/ដើមឈើ លើផ្ទៃដីតែមួយជាមួយគ្នា ហើយមុខដំណាំអាចផ្លាស់ប្តូរ ឬដាំឡើងវិញតាមកាលវេលា)។







# ➢ ចំណាត់ថ្នាក់នៃប្រព័ន្ធកសិរុក្ខកម្ម(ត)

2. ប្រព័ន្ធបសុរុក្ខវប្បកម្ម
*(Silvi-Pastoral system)*





- ប្រព័ន្ធរុក្ខបសុសត្វវប្បកម្មសំដៅលើ ដើមឈើ និងការចិញ្ចឹមសត្វ (ការដាំដុះព្រៃឈើ និងការចិញ្ចឹមសត្វនៅក្នុង ឬរកចំណីក្នុងទីព្រៃនោះ)។ ប្រព័ន្ធទី២នេះ ជាការចិញ្ចឹមសត្វឱ្យស៊ីស្មៅនៅក្រោមដើមឈើធំៗ ឬព្រៃឈើមានស្រាប់ក្នុងសហគមន៍ ចម្ការឈើដាំសម្រាប់យកផលឈើ ឬ ដំណាំឈើហូបផ្លែ។ ប្រភេទសត្វចិញ្ចឹមមានដូចជា គោ ក្របី ពពែ ចៀម ជាដើម។

# ➢ ចំណាត់ថ្នាក់នៃប្រព័ន្ធកសិរុក្ខកម្ម( ត )

### 3. ប្រព័ន្ធកសិបសុរុក្ខវប្បកម្ម
*(Agri-Silvi-Pastoral System)*

- ប្រព័ន្ធកសិរុក្ខបសុសត្វវប្បកម្មសំដៅលើ ការដាំដំណាំកសិកម្ម ដើមឈើ និងការចិញ្ចឹមសត្វ (ការដាំដុះបញ្ចូលគ្នារវាងដំណាំកសិកម្ម ព្រៃឈើ កូនឈើ/ដើមឈើ និង ការចិញ្ចឹមសត្វនៅលើផ្ទៃដីតែមួយជាបន្តបន្ទាប់)។ ប្រព័ន្ធប្រភេទនេះអាចបំលែងជាប្រព័ន្ធរុក្ខបសុសត្វវប្បកម្មដែលមានវត្តមានតែដើមឈើ នឹងសត្វចិញ្ចឹម។







# ➢ ចំណាត់ថ្នាក់នៃប្រព័ន្ធកសិរុក្ខកម្ម( ត )

## 4. ប្រព័ន្ធកសិរុក្ខកម្មចម្រុះ

*(Integrated Agroforestry System)*

- ប្រព័ន្ធកសិរុក្ខកម្មចម្រុះសំដៅលើការអនុវត្តកសិរុក្ខកម្ម បសុវប្បកម្ម និងវារីវប្បកម្ម (ការដាក់បញ្ចូលគ្នារវាងដំណាំកសិកម្ម ដើមឈើ បសុសត្វ និងវារីវប្បកម្ម) រួមមាន ការដាំដំណាំកសិកម្មជាមួយដើមឈើដាំ ឬឈើមានស្រាប់ដោយមានការចិញ្ចឹមសត្វ (គោ ក្របី ពពែ...) និងការចិញ្ចឹមត្រី នៅក្នុងសហគមន៍ព្រៃឈើ។



# ពូជដំណាំ ពូជដើមឈើ ពូជសត្វ និងពូជត្រីដែលបានអនុញ្ញាតឱ្យដាំនៅក្នុងកសិរុក្ខកម្ម

- ពូជដំណាំកសិកម្មដែលដាំដុះក្នុងប្រព័ន្ធកសិរុក្ខកម្មអាចជាដំណាំរយៈពេលខ្លី (រមៀត រំដេង ខ្ញី ត្រាវ សណ្ដែកដី ដំឡូងជ្វា សណ្ដែកគួរ ត្រសក់ ពោត...) និងដំណាំរយៈពេលមធ្យម (ដំឡូងដៃខ្លា ម្នាស់ អំពៅ ស្លឹកគ្រៃ...) តាមចំណង់ចំណូលចិត្ត តាមតម្រូវការទីផ្សារ និងការបរិភោគរបស់សហគមន៍។
- រុក្ខវប្បកម្ម សំដៅលើការដាំឈើ ឬដាំជាចម្ការ ដើម្បីបន្ថែមឈើដែលមានតម្លៃសេដ្ឋកិច្ចចូលក្នុងព្រៃឈើ ឬចម្ការឈើ។ ពូជឈើដែលមានតម្លៃសេដ្ឋកិច្ច និងបរិស្ថាន មានដូចជា គ្រញូង ធ្នង់ បេង នាងនួន ខ្វាវ ឬឈើសំណង់មាន ឈើទាល ផ្ចឹក ត្រាច ខ្លុង ត្បែង ជាដើម តាមតម្រូវការប្រើប្រាស់ ឬតម្រូវតាមតំបន់អេកូឡូស៊ី។ ការជ្រើសរើសដំណាំកសិកម្មទាំងនេះមកដាំក្នុងព្រៃឈើសហគមន៍ ដែលមានគម្របម្លប់ខ្ពស់នោះ គួរតែជ្រើសរើស ដំណាំណាដែលមានភាពធន់នឹងម្លប់ អាចដាំដុះជាមួយព្រៃឈើ និងដើមឈើដែលបានដុះរួចមកហើយ។
- វារីវប្បកម្ម (ការចិញ្ចឹមត្រី) នៅក្នុងសហគមន៍ព្រៃឈើត្រូវជ្រើសរើសពូជត្រីដែលមិនមានហានិភ័យដល់បរិស្ថាន។ វារីវប្បកម្មអាចធ្វើឡើងក្នុងស្រះទឹកសហគមន៍ ដែលស្រះទឹកនេះអាចរក្សាទឹកសម្រាប់គោផឹកនៅពេលរដូវប្រាំងខ្វះទឹក។
- ការចិញ្ចឹមសត្វមានដូចជា គោ ក្របី ពពែ ចៀម គួរជ្រើសរើសតាមតម្រូវការសហគន៍ និងតម្រូវការក្នុងស្រុក ឬក្រៅស្រុក ដែលបម្រើផលប្រយោជន៍សហគមន៍ សង្គម និងសេដ្ឋកិច្ច បរិស្ថានធម្មជាតិ។
- វារីវប្បកម្ម (ការចិញ្ចឹមត្រី) នៅក្នុងសហគមន៍ព្រៃឈើ គួរជ្រើសរើសប្រភេទត្រីដូចជា អណ្ដែង រ៉ស់ ក្រាញ់ ទីឡាព្យា... ដែលងាយស្រួលក្នុងការចិញ្ចឹម។

# ២.ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូព្រិច

## ២. ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច

❑ **ការធ្វើឱ្យប្រសើរឡើងលើដីបម្រុងទុក** ( Improved fallows )

- អនុវត្តលើដី ដែលស្ថិតនៅក្នុងរយៈពេលបម្រុងទុក (Fallow) ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងគុណភាពដី ពន្លឿនការដុះលូតលាស់ឡើងវិញនូវរុក្ខជាតិដុះថ្មី ការទប់ទល់ស្មៅចង្រៃ និងការបង្កើនជីវៈចម្រុះ

...





## ២. ការអនុវត្តកសិរុក្ខកម្មនៅតំ

❑ **តុងយ៉ា** ( Taungya )

- តុងយ៉ា(Taungya) ជាពាក្យមកពីភាសាភូមា តុង (Taung) មានន័យថាភ្នំ (Hill) និង យ៉ា(Ya) មាន ន័យថា ការដាំដុះ (Cultication) ពោលគឺសំដៅលើការអនុវត្តន៍ ការដាំដុះដំណាំកសិរុក្ខកម្មជាមួយឈើដាំ ក្នុងអំឡុងពេ ២ឆ្នាំ ទៅ ៣ឆ្នាំ ដំបូង នៃការស្តារតាមតំបន់ជម្រា
- ការអនុវត្ត តុងយ៉ា(Taungya) ភាគច្រើនគេប្រើពូជ  មួយចំនួនដូចជា៖ ដើមម៉ៃសាក់ (Tectona grandis) ដើមប្រេងខ្យល់ (Eucalypyus camaldulensis) Gmeline arborea (Shorea robusta), Terminalia superba, (Pinus spp) St Cupressus spp (Lamprecht 1989, Mac Dicken 1990)





## ២. ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច ( ត )

❑ **ការដាំដំណាំជាជួរចន្លោះឆ្លាស់** ( Alley Cropping )

- ការដាំដំណាំតាមលក្ខណៈងាយៗនៅចន្លោះរង (Hedgerow) នៃដើមឈើ និងចុល្លព្រឹក្សា ភាគច្រើនជាប្រភេទដើមឈើលេគុលមីនី (leguminous)
- ដើមឈើត្រូវកាត់តម្រឹមយូរៗម្តង ដើម្បីការពារកុំឱ្យមានម្លប់ទៅគ្របលើដំណាំដែលស្ថិតក្នុង ជួរចន្លោះក្បែរៗនោះ។





## ២. ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច ( ត )





❑ **គេហសួន** Home Garden

គេប្រើប្រាស់យ៉ាងទូលាយ ដើម្បីសម្គាល់នូវការអនុវត្តន៍ ផ្សេងគ្នានៃការដាំដើមឈើហូបផ្លែ និងសួនបន្លែដុះវិញលំនៅស្ថានដែលមានលក្ខណៈជាប្រព័ន្ធចំការឈើច្រើនស្រទាប់។

# ២.ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច(ត)

## ២. ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច (ត)





- ចំការដំណាំចម្រុះ (Plantation Crop combination)
  - ការដាំដុះចំការដំណាំចម្រុះច្រើនប្រភេទ នៅក្នុងទីតាំងតែមួយ ដោយមានដំណាំរយៈខ្លី និងវែងចម្រុះគ្នា ដើម្បីបង្កើនសេដ្ឋកិច្ចគ្រួសារ
  - ការអនុវត្ត ភាគច្រើនផ្តោតសំខាន់លើប្រភេទដំណាំមានតម្លៃខ្ពស់ ដូចជា ដំណាំដូងប្រេង កៅស៊ូ ដូង កាហ្វេ កាកាវ តែ ស្វាយចន្ទី និងម្រេច។

## ២. ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច (ត)

- សួនដើមឈើច្រើនស្រទាប់ (Multistorey tree garden)
  - សំដៅលើការដាំចម្រុះជាស្រទាប់ ដូចជា ស្រទាប់ដើមឈើ និងស្រទាប់ដំណាំផ្នែកខាងក្រោម។
  - សួនដើមឈើច្រើនស្រទាប់នេះមានលក្ខណៈខុសពីគេហ៍សួន ដែលព័ទ្ធជុំវិញបរិវេណផ្ទះរៀងៗខ្លួន ហើយជាទូទៅ ប្រព័ន្ធនេះនៅឆ្ងាយពីផ្ទះ ភាគច្រើនស្ថិតនៅលើដីសហគម ន៍ដែលព័ទ្ធជុំវិញដោយភូមិករ។



រូបភាពទី៣.១៥ ប្រភេទដំណាំ និងដើមឈើនៅក្នុងសួនដើមឈើច្រើនស្រទាប់



រូបភាពទី៣.១៦ ស្រទាប់រុក្ខជាតិ និងដើមឈើនៅក្នុងសួនដើមឈើច្រើនស្រទាប់

## ២. ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច (ត)

- របាំងការពារខ្យល់ និងទីជម្រក
  - សំដៅលើការដាំដើមឈើជុំវិញចម្ការដំណាំ ឬជារបង ដើម្បីប្រើប្រាស់របាំងខ្យល់ ការពារដំណាំ ប្រភពទឹក និងភូមិករ...
  - ការដាំអាចជាជួរច្រើនស្រទាប់ អាចជារបងជុំវិញ....





# ៣.សារៈប្រយោជន៍នៃការបង្កើតកសិរុក្ខកម្ម

➢ **ការអនុវត្តប្រព័ន្ធកសិរុក្ខកម្មអាចផ្ដល់អត្ថប្រយោជន៍ជាច្រើនដល់ធនធានសេដ្ឋកិច្ចសង្គមនិងបរិស្ថាន ដូចខាងក្រោម៖**

- បង្កើនគម្របពណ៌បៃតងដល់ភពផែនដី ជួយទប់ស្កាត់ការប្រែប្រួលអាកាសធាតុ បន្ថយការហូរច្រោះដីនិងការកករងដីល្បាប់តាមផ្លូវទឹក ដែលសម្រេចបានតាមរយៈការកាត់បន្ថយនិងទប់ស្កាត់បានការហូរចម្រោះពីដីជម្រាល។
- កាត់បន្ថយសម្ពាធព្រៃឈើដែលសេសសល់ សម្រេចបានការបង្កើនផលិតភាពនៃដីកសិកម្មដែលមានស្រាប់និងដោយការបង្កើនការផ្គត់ផ្គង់អុសនិងអនុផលព្រៃឈើផ្សេងៗទៀត។
- ធ្វើឱ្យប្រសើរឡើងមីក្រូអាកាសធាតុ តាមរយៈការកើនឡើងនៃជីវម៉ាសដែលមានអត្ថប្រយោជន៍ដល់ ដំណាំសត្វ និង មនុស្សដែលជាលទ្ធផលបានមកពីឥទ្ធិពលនៃដើមឈើទៅលើមីក្រូអាកាសធាតុ។
- ទិន្នផលដំណាំនិងសត្វកើនឡើងនិងមាននិរន្តរភាពជាងមុន ងៃលជាលទ្ធផលដោយផ្ទាល់ដោយការគាំពារពីដើមឈើឬដោយប្រយោលតាមរយៈការរួមចំណែករបស់ដើមឈើឬដោយប្រយោលតាមរយៈការរួមចំណែករបស់ដើមឈើដូចជា ការពារខ្យល់ រក្សាប្រភពទឹកក្រោមដី បង្កើនជីជាតិដី រចនា-សម្ព័ន្ធដី។ល។
- កាត់បន្ថយសម្ពាធលើដីវាលស្មៅ ដោយដើមឈើបានផ្ដល់ស្លឹក ត្រួយ ផ្លែ គ្រាប់ ជាចំណីសត្វចិញ្ចឹម។
- ប្រាក់ចំណូលកាន់តែខ្ពស់សម្រាប់កសិករខ្នាតតូច និងអ្នកប្រើប្រាស់ដីផ្សេងៗទៀតដែលទទួលបានមកពីការលក់ផលិតផលកសិកម្មនិងអនុផលព្រៃឈើ។
- កាត់បន្ថយការពឹងផ្អែកលើប្រភពខាងក្រៅសម្រាប់ធាតុចូលកសិកម្មសំខាន់ៗ(ជី)និងផ្ដល់នូវគ្រឿងឧបភោគ បរិភោគដូចជា៖ អាហារ អុស សម្ភារៈសំណង់និងឱសថជាដើម ដែលជាផលិតផលបានមកពីការចូលរួមផ្គត់ផ្គង់នៃព្រៃឈើ។

➢ **អត្ថប្រយោជន៍ពីការអនុវត្តកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើ**

- ការអនុវត្តកសិរុក្ខកម្មអាចជួយបង្កើនគម្របព្រៃឈើឡើងវិញ តាមរយៈការដាំបន្ថែមតាមចន្លោះរងដំណាំកសិកម្ម និងបង្កើតការដាំដំណាំកសិកម្មនៅតាមចន្លោះជួរដើមឈើដែលបានដាំ។
- បង្កើនការដាំដំណាំកសិកម្ម តាមចន្លោះជួរឈើដាំដែលមិនទាន់គ្របម្លប់ពេញលេញ ឬតាមចន្លោះជួរឈើដាំដែលមានគម្លាតសមស្របសម្រាប់ការដាំបន្ថែមដំណាំកសិកម្មជាអចិន្ត្រៃយ៍
- បង្កើនចំណូល និងគ្រឿងឧបភោគ បរិភោគជូនដល់សមាជិកក្រុមកសិរុក្ខកម្ម
- ដើមឈើនឹងបង្កើនជីជាតិដី ដែលបង្កើនទិន្នផលដល់ដំណាំកសិកម្ម ការពារដំណាំពីខ្យល់ព្យុះ ការពារការហូរច្រោះ រក្សាប្រភពទឹកក្រោមដី បង្កើតជាមីក្រូអាកាសធាតុដែលអំណោយផលដល់ការដាំដុះ បង្កើនជីវចម្រុះ និងប្រភេទសត្វដែលមានប្រយោជន៍ដល់កសិកម្មនិងជួយសម្របដល់ទំនាក់ទំនងកសិអេកូឡូស៊ីឱ្យមានភាពល្អប្រសើរ។
- ចូលរួមការកាតបន្ថយការប្រែប្រួលអាកាសធាតុនៅលើភពផែនដី។
- ក្រុមកសិរុកក្ខកម្មទទួលបានអាហារូបត្ថម្ភ ប្រកបដោយសុវត្ថិភាព និងសន្តិសុខស្បៀងគ្រប់គ្រាន់ មានប្រាក់ចំណូលបន្ថែម។
- តាមរយៈគណៈកម្មការនិងសមាជិកមកបំពេញការងារនៅក្នុងកសិរុក្ខកម្ម ជួយការពារព្រៃសហគមន៍ កាត់បន្ថយបទល្មើសកាប់ព្រៃឈើ បរបាញ់សត្វបាន។
- មានបដិភាគចូលរួមក្នុងសហគមន៍តាមរយៈការដកភាគរយពីក្រុមអនុវត្តកសិរុក្ខកម្ម ដើម្បីដំណើរការតណទានសហគមន៍ព្រៃឈើ។
- ធ្វើឱ្យមានកំណើតសត្វព្រៃ សត្វក្ងាន ខ្ទីង ....សត្វស្លាប សត្វកម្រនៅក្នុងព្រៃឡើងវិញ។
- ធ្វើឱ្យអនិផលព្រៃឈើមានការកើនឡើង ដូចជាទឹកឃ្មុំព្រៃធម្មជាត់ ផ្សិត ផ្ដៅ... ដែលបានជួយលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានឱ្យមានលក្ខណៈល្អប្រសើរ។
- បង្កើតតំបន់អេកូទេសចរណ៍ធម្មជាតិ ដែលអាចរកប្រាក់ចំណូលជូនដល់សហគមន៍មូលដ្ឋាន និងចូលរួមលើកកម្ពស់សេដ្ឋកិច្ចជាតិឱ្យភាពរីកចម្រើនប្រកបដោយចីរភាព។

# ជំហាននៃការបង្កើតកសិរុក្ខកម្មមាន៨ជំហាន

**8th** ការត្រួតពិនិត្យនិងវាយតម្លៃ

**7th** ការប្រមូលផលនិងការបែងចែកផលប្រយោជន៍

**6th** ការថែទាំនិងប្រតិបត្តិការងារកសិរុក្ខកម្ម

**5th** ការរៀបចំផែនការសម្រាប់ការដាំដុះ និងអនុវត្តន៍

**4th** ការបណ្តុះបណ្តាលបច្ចេកទេសកសិរុក្ខកម្

**3rd** រចនាសម្ព័ន្ធក្នុងការអនុវត្តកសិរុក្ខកម្ម

**2nd** ការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ

**1st** កំណត់ទីតាំងកសិរុក្ខកម្ម និងការផ្សព្វផ្សាយ

# ការកំណត់ទីតាំងកសិរុក្ខកម្ម

- ការកំណត់ទីតាំងនិងការកំណត់ព្រំប្រទល់ដោយមាននិយាមការ ដើម្បីផលិតជាផែនទីតំបន់កសិរុក្ខកម្ម។ខាងក្រោមនេះជារូបផែនទី ជាឧទាហរណ៍ក្នុងការបង្កើតជាផែនទីទីតាំងអនុវត្តកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើឆែប លិច។









# រចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ



# រចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងកសិរុក្ខកម្ម



# អ្នកពាក់ព័ន្ធ និងតួនាទីក្នុងការចូលរួមអភិវឌ្ឍន៍កសិរុក្ខកម្ម

| តួនាទីរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល/ជាតិ | តួនាទីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | តួនាទីអង្គការដៃគូរពាក់ព័ន្ធ |
|---|---|---|
| ដើម្បីឱ្យការអនុវត្តកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើ ទទួលបានជោគជ័យ អ្នកពាក់ព័ន្ធត្រូវចូលរួមយ៉ាងសកម្មក្នុងការជួយសម្រួបសម្រប ផ្តល់បច្ចេកទេស ស្វែងរកទីផ្សារ និងកៀរគរធនធានថវិកា ដើម្បីជួយជំរុញការអនុវត្តកសិរុក្ខកម្មឱ្យទទួលបានប្រសិទ្ធភាព។<br>ឯកសារផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពស្តីពីកសិរុក្ខកម្ម បានបង្ហាញពីរចនាសម្ព័ន្ធគ្រប់គ្រងកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើ ដែលមានចាប់ពីកម្រិតថ្នាក់ជាតិ/ថ្នាក់កណ្តាល រហូតទៅដល់កម្រិតសហគមន៍ព្រៃឈើ។ រចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍ព្រៃឈើចែកចេញជា ៤ ក្រុម ក្នុងនោះរួមមាន ក្រុមស្តារព្រៃឈើ ក្រុមល្បាត ក្រុមតំណាង និងក្រុមកសិរុក្ខកម្ម ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ។ តួនាទីរបស់អ្នកពាក់ព័ន្ធសំខាន់ៗមានដូចខាងក្រោម៖<br>**៥.១ តួនាទីរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល/ជាតិ**<br>រដ្ឋបាលព្រៃឈើ នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ ការិយាល័យសហគមន៍ព្រៃឈើ ការិយាល័យកសិរុក្ខកម្ម ក៏ដូចជាក្រុមការងារបច្ចេកទេសកំណែទម្រង់ព្រៃឈើ (TWG-FR) មានតួនាទីសំខាន់ៗ ពាក់ព័ន្ធការងារកសិរុក្ខម្មដូចខាងក្រោម៖<br>• ពន្លឿនការការធ្វើវិសោធនកម្មច្បាប់ព្រៃឈើ និងលិខិតបទដ្ឋានក្រោមច្បាប់ ពិសេសបទដ្ឋានពាក់ព័ន្ធនឹង សហគមន៍ព្រៃឈើ គោលការណ៍ណែនាំកសិរុក្ខកម្ម និងឯកសារពាក់ព័ន្ធផ្សេងៗ<br>• គាំទ្រ និងជំរុញការអនុវត្តកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើឱ្យមានដំណើរការកាន់តែល្អប្រសើរ<br>• កៀរគរមូលនិធិ ដើម្បីគាំទ្រដល់ការអនុវត្តការងារកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើ និងការគ្រប់គ្រងសហគមន៍ព្រៃឈើ<br>• តាមដានពីការប្រែប្រួលគម្របព្រៃឈើនៅក្នុងទីតាំងសហគមន៍ព្រៃឈើ<br>• ជួយពង្រឹងការគ្រប់គ្រងសហគមន៍តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់<br>• រៀបចំឯកសារបច្ចេកទេសអំពីកសិរុក្ខកម្ម និងការដាំឈើ<br>• ស្រាវជ្រាវ និងផ្សព្វផ្សាយពីបច្ចេកទេសដាំឈើ ដាំដំណាំកសិកម្ម ចិញ្ចឹមសត្វ និងវារីវប្បកម្ម<br>• ចាត់មន្ត្រីចុះជួយពង្រឹងសហគមន៍ និងការងារកសិរុក្ខកម្ម | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតួនាទី និងភារកិច្ចក្នុងការអនុវត្តកសិរុក្ខកម្មដូចខាងក្រោម៖<br>• ខណ្ឌ/ផ្នែក/សង្កាត់រដ្ឋបាលព្រៃឈើ ជួយគាំទ្រលើផ្នែកគ្រប់គ្រងសហគមន៍ព្រៃឈើ និងជួយផ្នែកបច្ចេកទេសដាំកូនឈើ និងការថែទាំ<br>• ការិយាល័យក្សេត្រសាស្ត្រ ជួយគាំទ្រផ្នែកបច្ចេកទេសដាំដុះដំណាំកសិកម្ម (បន្លែ ផ្លែឈើ...)<br>• ការិយាល័យផលិតកម្ម និងបសុសត្វព្យាបាល ជួយគាំទ្រផ្នែកបច្ចេកទេសចិញ្ចឹមសត្វ មាន់ ទា គោ ក្របី<br>• ការិយាល័យជលផល នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជួយគាំទ្រផ្នែកបច្ចេកទេសវារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប...)<br>• ស្វែងរកមូលនិធិគាំទ្រ និងទីផ្សារ ជូនក្រុមកសិរុក្ខកម្ម របស់សហគមន៍ព្រៃឈើ<br>• ជំរុញការអនុវត្តកសិរុក្ខកម្ម នៅក្នុងសហគមន៍ព្រៃឈើ<br>• ជួយគាំទ្របច្ចេកទេសផ្សេងៗទៀត ដូចជាការរៀបចំផែនការកសិរុក្ខកម្មក្នុងសហគមន៍ព្រៃឈើ<br>**៥.៣ តួនាទីអាជ្ញាធរមូលដ្ឋាន ស្រុក ឃុំ ភូមិ**<br>• គាំទ្រ និងលើកទឹកចិត្តដល់ការអនុត្តកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើ<br>• ចូលរួមសម្របសម្រួលដោះស្រាយទំនាស់ដីនៅក្នុងសហគមន៍ក្នុងករណីមានការបំពានខុសច្បាប់។<br>• ស្វែងរកមូលនិធិគាំទ្រ និងទីផ្សារ ជូនក្រុមកសិរុក្ខកម្ម របស់សហគមន៍ព្រៃឈើ<br>**៥.៤ តួនាទីសហគមន៍ព្រៃឈើ និងក្រុមកសិរុក្ខកម្ម**<br>• ជ្រើសរើសក្រុមការងារដែលមានឆន្ទៈ និងមានចំណូលចិត្តក្នុងការចូលរួមអនុវត្តកសិរុក្ខកម្ម<br>• ក្រុមការងារកសិរុក្ខកម្មត្រូវឯកភាពគ្នាអនុវត្តតាមកម្មវិធីការងារ និងប្រតិទិនការងារដែលបានដាក់ចេញ<br>• បែងចែកជាវេន ក្នុងការថែទាំ ស្រោចទឹក ទាំងប្រភេទកូនឈើ ដែលបានដាំ និងដំណាំផ្សេងៗទៀតតាមកាលវិភាគ<br>• ប្រជុំក្រុមរៀងរាល់ពីរសប្តាហ៍ម្តង ឬប្រចាំខែ ទៅតាមការព្រមព្រាងក្នុងក្រុមកសិរុក្ខកម្ម។ | **៥.៥ តួនាទីអង្គការដៃគូរពាក់ព័ន្ធ**<br>• ជួយគាំទ្រសហគមន៍ក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព<br>• ជួយគាំទ្រជំនួយបច្ចេកទេស និងសម្ភារៈក្នុងការអនុវត្តកសិរុក្ខកម្ម ឱ្យមានភាពរីកចម្រើន ដើម្បីឱ្យសហគមន៍មានសមត្ថភាព បន្តការគ្រប់គ្រងដោយខ្លួនឯង. |

# ៦. ផែនការនិង ហិរញ្ញវត្ថុ

## ៦. ផែនការ និងហិរញ្ញវត្ថុ

ការរៀបចំផែនការអនុវត្តកសិរុក្ខកម្ម ឬគម្រោងកសិរុក្ខកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តម្រូវឱ្យមានវិសាលភាព និងការវិភាគស្ថានភាពដើម្បីកំណត់បញ្ហាចន្លោះប្រហោង និងឱកាស។ ដើម្បីឱ្យការអនុវត្តកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើធានាបាននិរន្តរភាពក្នុងន័យស្តារធនធានព្រៃឈើ ជីវៈចម្រុះ ការធ្លាក់ចុះគុណភាពដី ទាំងក្នុងកម្រិតសហគមន៍ នឹងកម្រិតផែនទេសភាព ផែនការហិរញ្ញវត្ថុនៅក្នុងសហគមន៍ព្រៃឈើ ទាំងរយៈពេលមធ្យម នឹងរយៈពេលវែង ត្រូវរៀបចំជាចាំបាច់។ ការធ្វើផែនការហិរញ្ញវត្ថុនៅកម្រិតសហគមន៍ព្រៃឈើ គួរតែត្រូវបានជួយគាំទ្រដោយស្ថាប័នជំនាញ និងអង្គការដៃគូពាក់ព័ន្ធ។ ផែនការហិរញ្ញវត្ថុនេះ ត្រូវមានប្រភពគាំទ្រច្បាស់លាស់ ហើយបញ្ចូលក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់។ សង្កាត់/ផ្នែក/ខណ្ឌរដ្ឋបាលព្រៃឈើ តាមបណ្តាខេត្ត ដើរតួនាទីសំខាន់ ជាអ្នកគាំទ្រថវិកា(តាមរយៈថវិការដ្ឋ) និងជាអ្នកកៀរគរថវិកាពីស្ថាប័ន អង្គការដៃគូ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។ ធនធានថវិកាក្នុងការអនុវត្តកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើ អាចមានប្រភពមកពី រាជរដ្ឋាភិបាលកម្ពុជា អង្គការដៃគូរ ដៃគូអភិវឌ្ឍន៍ សប្បុរសជន វិស័យឯកជន និងចំណូលផ្សេងៗទៀតពីសហគមន៍ខ្លួនឯង។ គួរតែកំណត់ឱ្យបានច្បាស់ថា ការរៀបចំដំណើរការកសិរុក្ខកម្ម ក្នុងសហគមន៍ព្រៃឈើនេះជាបឋមគឺជាការធ្វើវិនិយោគមួយដែលអាចធានាបាននូវចំណូលសម្រាប់ជីវភាពរបស់សមាជិកក្រុមកសិរុក្ខកម្ម ធនធានថវិកាគឺជាតម្រូវការចាំបាច់សម្រាប់តែការចាប់ផ្តើមដំណើរការក្នុងរយៈពេលមុនពេលទទួលផលពេញលេញប៉ុណ្ណោះ។ ផ្ទុយទៅវិញ ប្រសិនបើកសិរុក្ខកម្មសម្រាប់ការការពារទីជម្រាល ឬតំបន់ការពារពិសេសណាមួយ គឺចាំបាច់ត្រូវតែគិតគូរពីកម្រៃសេវាកម្មបរិស្ថាន ដើម្បីគាំទ្រជីវភាពសហគមន៍។

# ៧. បទពិសោធន៍នៃការបង្កើតនិងគ្រប់គ្រងកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើ

| សកម្មភាព | លទ្ធផល | រូបភាព |
|---|---|---|
| ➢ នៅក្នុងឆ្នាំ២០២២ អង្គការ WWF Cambodia បានរៀបចំនិងបង្កើតកសិរុក្ខកម្មចំនួន៥ នៅក្នុងសហគមន៍ព្រៃឈើចំនួន៥ CF គឺ កសិរុក្ខកម្ម ប្រាសាទទឹកខ្មៅ អូរក្រសាំង អូរកក់ ប៉ាក្លែ និងវាលកន្សែង។<br>➢ ចាប់ពីខែកក្កដា ២០២៣មក អង្គការFLO បានគ្រប់គ្រងកសិរុក្ខកម្មអូរកក់បន្ត នឹងគាំទ្រសកម្មភាពល្បាតសហគមន៍ព្រៃឈើទាំង៥ រួមទាំងក្រុម CF credit , Mini-Trust Fund .<br>➢ FLO បានផ្តល់វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេកចិញ្ចឹមគោ បច្ចេកទេសដំណាំ បច្ចេកទេកដាំបន្លែតាមបែបធម្មជាតិ របៀបផលិតជីកំប៉ុស្តិ៍ ភាពជាអ្នកដឹកនាំ និងរបៀបសរសេររបាយការណ៍ហិរញ្ញវត្ថុ របៀបសរសេរគម្រោងសំណើរខាតតូច បច្ចេកទេសដាំដំណាំកម្របដី | ➢ កសិរុក្ខកម្មទាំង៥ នៅក្នុងខេត្តក្រចេះ កំពុងតែមានដំណើរការគ្រប់គ្រងល្អ។<br>➢ គណៈកម្មការនិងសមាជិកមានចំណេះដឹងផ្នែកបច្ចេកទេសដាំដុះបន្លែធម្មជាតិ របៀបធ្វើជីកំប៉ុស្តិ៍ បច្ចេកទេសចិញ្ចឹមគោ ការគ្រប់គ្រងហិរញ្ញវត្ថុ របៀបសរសេរសំណើរខ្នាតតូច បានយល់ដឹងច្បាស់ពីសិទ្ធិនិងតួនាទីរបស់បុរសនិង ស្ត្រី មានជំនាញភាពជាអ្នកដឹកនាំនិងគ្រប់គ្រងក្រុម ។<br>➢ ព្រៃឈើ សត្វព្រៃ សត្វស្លាប ឃ្មុំព្រៃ សត្វកម្រជិតផុតពូជ មានចំនួនកើនឡើងវិញច្រើន ។<br>➢ អនុផលព្រៃឈើមានការកើនឡើង ដូចជា ផ្សិត ផ្តៅ ទឹកឃ្មុំព្រៃធម្មជាតិ ……ដែលបានចូលរួមលើកកម្ពស់ជីវភាពសហគមន៍នៅតាមទីកន្លែងដាច់ស្រយាល ពិសេសជនជាតិដើមភាគតិច បានល្អប្រសើរ។<br>➢ បានចូលរួមទប់ស្កាត់ បទល្មើស កាប់ព្រៃឈើ កាប់ព្រៃយកដី បរបាញ់សត្វ។<br>➢ កសិរុក្ខកម្មជាកន្លែងផ្សព្វផ្សាយបច្ចេកកសិកម្មបែបអភិរក្សទៅដល់សហគមន៍ដដៃ និងក្រុមយុវជន ជាយន្តការយ៉ាងសំខាន់ ដើម្បីឱ្យសហគមន៍មានភាពជាម្ចាស់នាពេលអនាគត។<br>➢ កសិរុក្ខកម្មនឹងសហគមន៍ព្រៃឈើទាំង៥នៅក្នុងខេត្តក្រចេះ នាពេរលអនាគតនឹងអាចក្លាយទៅជាតំបន់អេកូទេសចរធម្មជាតិបាន ដែលជាប្រភពមួយដ៏សំខាន់ក្នុងការបង្កើនប្រាក់ចំណូលរបស់សហគមន៍មូលដ្ឋាននិង ជួយអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិឱ្យមានភាពរីកចម្រើនប្រកបដោយចីរភាពផងដែរ។ |  |



# THANK YOU



FLO - Forests and Livelihoods Organization